# ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ ឆ្នាំម្សាញ់ ឆ្នាំ២០២៥

*ដោយ :* **លោកស្រីបណ្ឌិត ជា វណ្ណី**
*ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រនិងយេនឌ័រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរជិតចូលមកដល់ គឺនៅសល់តែជាង១០ថ្ងៃទៀតប៉ុណ្ណោះ ដែលក្នុងឱកាសនោះ ជាទូទៅប្រជាជនខ្មែរគ្រប់រូបនឹងធ្វើដំណើរពីគ្រប់ទិសទីដែលខ្លួនបានទៅរស់នៅឬទៅបំពេញការងារផ្សេងៗ ហើយបាននាំគ្នាត្រលប់មកស្រុកកំណើតរបស់ខ្លួនវិញ ដើម្បីជួបជុំក្រុមគ្រួសាររៀងរាល់មួយឆ្នាំម្តង ដោយមានការរៀបចំបោសជូតសម្អាតផ្ទះសម្បែង និងតុបតែងលម្អនូវរណ្តាប់ទទួលទេវតាទៅតាមការពេញចិត្តនិងចំណង់ចំណូលចិត្តរបស់ខ្លួនផងដែរ។ គ្រឿងរណ្តាប់ដែលត្រូវរៀបនោះគឺគេក្រាលសំពត់ពណ៌សនៅលើតុ ឬលើទីដែលខ្ពស់សមរម្យ ដោយរៀបចំនូវគ្រឿងសក្ការបូជាទេវតាដែលមានដូចជា បាយសី៩ថ្នាក់មួយគូ បាយសី៧ថ្នាក់មួយគូ បាយសី៥ថ្នាក់មួយគូ បាយសី៣ថ្នាក់មួយគូ បាយសីប៉ាឆាមមួយគូ ស្លាធម៌មួយគូ ទៀន៥ ធូប៥ លាច៥ ផ្កា៥ ដាក់លើជើងពានមួយគូ ចេកណាំវ៉ាដាក់លើជើងពានមួយគូ ផ្លែឈើ១១មុខ(អាស្រ័យតាមធនធានដែលមាន)រៀបដាក់ជើងពានមួយគូ ដូងឡៅមួយគូ ទឹកស្អាតពីរកែវ ហើយបើមានផ្កាម្លិះភួង គេក៏យកភួងម្លិះទាំងនោះទៅដាក់នៅលើគ្រប់ជង្វាយទាំងអស់ ក៏កាន់តែប្រសើរ។ ចំណែកនៅលើបាយសីត្រូវដោតទៀន ហើយដុតទៀននោះបំភ្លឺផងដែរ។*

*តើយើងគួរយល់ដឹងពីអ្វីខ្លះនៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរយើងនេះ?*

## ១. អំពីទេវតា

*ឆ្នាំនេះឆ្នាំថ្មីប្រពៃណីខ្មែរនឹងឈានចូលឆ្នាំថ្មីនៅវេលាម៉ោង៤និង៤៨នាទីទៀប*

ភ្ជី គឺត្រូវនឹងថ្ងៃចន្ទ ២រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៥។ ទេវតាឆ្នាំថ្មីឆ្នាំនេះ មានព្រះនាមថា **គោរាគៈទេវី** ជាបុត្រីទី២នៃកបិលមហាព្រហ្ម ដោយអម្ពរពណ៌លឿងលំអរព្រះការណ៍ដោយសៀតផ្កាអង្គាបុស្ស គង់បិទព្រះនេត្រលើខ្នងស្តេចខ្លាពោរពេញដោយភាពក្លាហាននិងមានបារមី ព្រះហស្តឆ្វេងទ្រង់ព្រះខ័ន និងព្រះហស្តឆ្វេងទ្រង់ឈើច្រត់ ហើយព្រះនាងសោយប្រេង (សណ្តែក/ល្ង)។

សូមបញ្ជាក់ថា ទេវតាដែលចុះមកឃុំគ្រងថែរក្សាទ្វីបលោក គឺបុត្រីទាំង៧នៃកបិលមហាព្រហ្មជាអ្នកប្តូរវេនគ្នាទៅតាមថ្ងៃនៃថ្ងៃសង្ក្រាន្តឆ្នាំថ្មី។ បើសង្ក្រានចំ**ថ្ងៃអាទិត្យ** ត្រូវនាង**ទុង្សាទេវី** ដែលមានសម្លៀកបំពាក់ពណ៌ក្រហម សៀតផ្កាទទឹម គ្រឿងប្រដាប់បទុមរាគ ភក្សាហារផ្លែឧទុម្ពរ(ល្វា) ព្រះហស្តស្តាំកាន់កងចក្រ ព្រះហស្តឆ្វេងកាន់ស័ង្ខ និងមានពាហនៈគ្រុឌជាយានជំនិះ។ បើសង្ក្រានត្រូវចំ**ថ្ងៃច័ន្ទ** ត្រូវវេននាង**គោរាគៈទេវី** ដែលមានសម្លៀកបំពាក់ពណ៌លឿង សៀតផ្កាអង្គាបុស្ប គ្រឿងប្រដាប់មុក្តា(គជ់ខ្យង) ភក្សាហារប្រេង ព្រហស្តស្តាំកាន់ព្រះខ័ន ព្រះហស្តឆ្វេងកាន់ឈើច្រត់ និងមានពាហនៈព្យគ្ឃ(ខ្លា)ជាយានជំនិះ។ បើសង្ក្រានត្រូវចំ**ថ្ងៃអង្គារ** នាង**រាក្សសាទេវី** ដែលមានសម្លៀកបំពាក់ពន៌ខ្មៅ សៀតផ្កាឈូក គ្រឿងប្រដាប់មោរ៉ា ភក្សាហារលោហិត ព្រហស្តស្តាំកាន់ត្រីសូល៍ ព្រះហស្តឆ្វេងកាន់ធ្នូនិងពាហនៈអស្សតរៈជាយានជំនិះ។ បើសង្ក្រានត្រូវចំ**ថ្ងៃពុធ** នាង**មណ្ឌាទេវី** មានសម្លៀកបំពាក់ពណ៌ផ្ទៃមេឃ សៀតផ្កាចំប៉ា គ្រឿងប្រដាប់ពិទូរ្យ ភក្សាហារទឹកដោះ ព្រហស្តស្តាំកាន់ម្ជុល ឆ្វេងកាន់ឈើច្រត់ មានពាហនៈលាជាយានជំនិះ។ បើសង្ក្រានត្រូវចំ**ថ្ងៃព្រហស្បត៍** នាង**កិរិណីទេវី** សម្លៀកបំពាក់ពណ៌បៃតង សៀតផ្កាមណ្ឌា គ្រឿងប្រដាប់មរកត ភក្សាហារសណ្តែក ល្ង ព្រហស្តស្តាំកាន់កង្វេរ ព្រះហស្តឆ្វេងកាន់ធ្នូ និងមានពាហនៈដំរីជាយានជំនិះ។ បើសង្ក្រានត្រូវចំ**ថ្ងៃសុក្រ** នាង**កិមិរាទេវី** ដែលមានសម្លៀកបំពាក់ពណ៌ស សៀតផ្កាចង្កុលណី(ប្រភេទពួកឈូកមានច្រើនស្រទាប់) គ្រឿងប្រដាប់បុស្សរាគ័ម(ថ្មើមថ្ម) ភក្សាហារចេកណាំវ៉ា ព្រហស្តស្តាំកាន់ព្រះខ័ន ព្រះហស្តឆ្វេងកាន់ពិណ និងមានពាហនៈក្របីជាយានជំនិះ។ បើសង្ក្រានត្រូវចំ**ថ្ងៃសៅរ៍** នាង**មហោទរាទេវី**

មានសម្លៀកបំពាក់ខៀវចាស់ សៀតផ្កាត្រកៀត គ្រឿងប្រដាប់នីលរតន៍ ភក្សាហារសាច់ទ្រាយ ព្រហស្តស្តាំកាន់ចក្រ ព្រះហស្តឆ្វេងកាន់ត្រីសូល៍ និងមានពាហនៈសត្វក្ងោកជាយានជំនិះ។

## ២. អត្ថន័យនៃពិធីបុណ្យចូលឆ្នាំ

ឆ្នាំចាស់បានកន្លងផុតទៅ ឆ្នាំថ្មីបានឈានចូលមកដល់ ជាគតិឱ្យយើងពិចារណានូវធម៌សង្វេកថា ពេលវេលាចេះតែកន្លងទៅជារៀងរាល់ឆ្នាំ ហើយអាយុកាលរបស់យើងគ្រប់គ្នាក៏អស់ទៅតាមឆ្នាំចាស់ដែលបានរសាត់បាត់ទៅ។ ដូច្នេះយើងមិនគួរប្រមាថមិនគួរប្រព្រឹត្តិអាក្រក់ មិនគួរឈ្លោះទាស់ទែងខ្វែងគំនិតគ្នា មិនគួរប្រកួតប្រជែងគ្នាមិនគួរលោភលន់ មិនគួរកាប់សម្លាប់គ្នា ឬដណ្តើមគ្នារស់នោះទេ គួរតែយើងចេះចែកគ្នារស់ លះបង់នូវទង្វើអាក្រក់ ប្រព្រឹត្តិតែទង្វើល្អ បណ្តុះនូវព្រហ្មវិហារធម៌ សាមគ្គីធម៌នៅក្នុងដួងចិត្តប្រកបដោយក្តីមេត្តា ករុណាឧបេក្ខា មុទិតា កតញ្ញូតា ឧបត្ថម្ភដល់ជីដូនជីតាមាតាបិតា ក៏ដូចជាព្រះសង្ឃ និងចែករំលែកទានដល់ជនដែលមានការខ្វះខាត ទីទាល់ក្រ ដែលជាទុរគតជន ក៏ដូចជាជនកំព្រា ឬអនាថាគ្មានទីពឹងប្រកបដោយក្តីអាណិតអាសូរ និងការស្រឡាញ់រាប់អាន។

ក្រៅពីអត្ថន័យនៃការឆ្លងឆ្នាំចាស់ផ្លាស់ឆ្នាំថ្មី ពិធីបុណ្យចូលឆ្នាំនេះ ក៏ជាការដើម្បីអបអរសាទរចំពោះមរតកកេរដំណែលរបស់បុព្វការីជន ក៏ដូចជាឱ្យចេះថែរក្សាការពារនូវប្រពៃណី ទំនៀមទម្លាប់នៃពិធីបុណ្យចូលឆ្នាំ របាំនិងល្បែងប្រជាប្រិយកុំឱ្យបាត់បង់ដោយប្រការផ្សេងៗ និងដើម្បីបង្ហាញពីភាពសប្បាយរីករាយរបស់ប្រជាជនខ្មែរ បន្ទាប់ពីប្រមូលផលរួច ក៏ដូចជាអបអរសាទរចំពោះធម្មជាតិ និងផលិតផលកសិកម្មដោយបណ្តុះនូវក្តីសង្ឃឹមនាឆ្នាំបន្តៗទៀត ហើយក៏ដើម្បីឧទ្ទិសបុណ្យកុសលដល់បុព្វការីជន មាតាបិតា ជីដូនជីតា ញាតកាសាច់សាលោហិត មិត្តសម្លាញ់ និងសព្វសត្វទាំងអស់ដែលបានចែកឋានទៅ និងដើម្បីបានសេចក្តីសុខចម្រើនសម្រាប់ខ្លួនឯងសម្រាប់ក្រុមគ្រួសារនិងសង្គមជាតិ ទាំងបច្ចុប្បន្នកាលនិងអនាគតកាល។

## ៣. ទំនៀមចូលឆ្នាំ

ទំនៀមពិធីចូលឆ្នាំប្រព្រឹត្តទៅចំនួន ៣ថ្ងៃ។ ថ្ងៃដំបូងឬថ្ងៃទី១ជាថ្ងៃ**មហាសង្ក្រាន្ត**

ថ្ងៃទី២ជាថ្ងៃ**វ័នបត** និងថ្ងៃទី៣ ជាថ្ងៃ**ឡើងស័ក**។ រីឯការកំណត់ខែ ថ្ងៃ ម៉ោង នាទីដែលឆ្នាំចាស់ត្រូវផុតកំណត់ ហើយទេព្តាឆ្នាំថ្មីត្រូវចុះមកទទួលតំណែងពីទេព្តាឆ្នាំចាស់នោះ គេអាចដឹងបានដោយប្រើក្បួនហោរាសាស្ត្របុរាណ គឺក្បួនមហាសង្ក្រាន្ត ដែលនៅសល់តែប៉ុន្មានថ្ងៃទៀតប៉ុណ្ណោះ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនឹងចូលមកដល់។ តាមមហាសង្ក្រាន្តឆ្នាំនេះ ចូលឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៨ គ.ស.២០២៥។ បុណ្យចូលឆ្នាំឆ្នាំនេះប្រព្រឹត្តទៅរយៈពេលបីថ្ងៃ គឺនៅថ្ងៃ២រោច ៣រោច និង៤រោច ខែចេត្រ ត្រូវនឹងថ្ងៃចន្ទ ទី១៤ ខែមេសា វេលាម៉ោង៤ និង៤៨នាទីទៀបភ្លឺ គឺថ្ងៃចន្ទ ទី១៤(ថ្ងៃមហាសង្ក្រាន) ថ្ងៃអង្គារ ទី១៥(ថ្ងៃវិរៈវ័នបត) និងថ្ងៃពុធ ទី១៦(ថ្ងៃវិរៈឡើងស័ក)។

## ពិធីទាំង៣ថ្ងៃនៃថ្ងៃចូលឆ្នាំ

**ថ្ងៃទី១៖** គេយកចង្ហាន់ទៅប្រគេនព្រះសង្ឃទាំងឡាយនៅតាមវត្តអារាម។ ពេលល្ងាច គេនាំគ្នាជញ្ជូនខ្សាច់សាងវាលុកចេតិយដែលមាននៅជុំវិញព្រះវិហារ ឬនៅជុំវិញដើមពោធិ៍ណាមួយនៅក្នុងវត្តនោះ។ នៅពេលព្រលប់ គេប្រគេនភេសជ្ជៈដល់ភិក្ខុ និមន្តភិក្ខុសូត្រចម្រើនព្រះបរិត្ត និងសំដែងធម៌ទេសនា។

**ថ្ងៃទី២៖** កូនចៅជូនសម្លៀកបំពាក់ នំចំណី លុយកាក់ ដល់អ្នកមានគុណ មានឪពុកម្តាយ ជីដូនជីតា ជាដើម។ ជួនកាលគេធ្វើទានដល់អ្នកបម្រើ ឬអ្នកក្រីក្រទៀតផង។ ពេលរសៀល គេនាំគ្នាទៅពូនភ្នំខ្សាច់ទៀត ហើយសូត្រធម៌អធិដ្ឋានភ្នំខ្សាច់ដែលគេសន្មត់ទុកដូចចូឡាមនីចេតិយ ហើយនិមន្តភិក្ខុបង្សុកូលចេតិយ បញ្ជូនមគ្គផលដល់វិញ្ញាណក្ខន្ធបងប្អូនដែលបានចែកឋានទៅ។

**ថ្ងៃទី៣៖** ពេលព្រឹកនិមន្តភិក្ខុសូត្រធ្វងភ្នំខ្សាច់។ ពេលល្ងាច និមន្តព្រះសង្ឃស្រង់ទឹក និងស្រង់ព្រះពុទ្ធរូប (តាមការនិយមនៃស្រុកខ្លះ) លុះត្រឡប់មកដលផ្ទះស្រង់ព្រះរស់មាន ជីដូនជីតា មាតាបិតា...។

សូមបញ្ជាក់ថា នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីនេះ គឺគេតែងតែនាំគ្នាលេងល្បែងប្រជាប្រិយកម្សាន្តសប្បាយជាច្រើនជារៀងរាល់ថ្ងៃ មានដូចជាលេង បោះអង្គុញ់ ចោលឈូង ទាញព្រ័ត្រ លាក់កន្សែង ដណ្តើមស្លឹកឈើ ស្តេចចង់ ឱបត្រឡាច ចាប់កូនខ្លែង ជាដើម និងមានរបាំត្រុដិ (ច្រើនមាននៅខេត្ត

បាត់ដំបង សៀមរាប) ជាពិសេសទៀតគឺរាំវង់ អាស្រ័យទៅតាមការនិយមចូលចិត្តរបស់បុគ្គលម្នាក់ៗ ហើយអ្នកខ្លះក៏និយមនាំគ្នាដើរកម្សាន្តតាមរមណីយដ្ឋាន អ្នកខ្លះនិយមធ្វើបុណ្យទានតាមវត្តអារាមនានា។

ក្រៅពីល្បែងកម្សាន្តទាំងនេះ កាលពីបុរាណក៏មានការលេងកម្សាន្តមួយប្រភេទទៀតហៅថា ពិធីប្រោះព្រំទឹក(ជះទឹក) នៅតាមភូមិផងដែរ គឺតាមទីលំនៅដ្ឋាននីមួយៗ តែងមានក្អមទឹក ឬធុងទឹកនៅពីមុខផ្ទះរបស់ពួកគេ ដោយមានអប់ផ្កាម្ទិះ ឬផ្កាផ្សេងៗឱ្យមានក្លិនក្រអូប ដើម្បីប្រោះឬជះទឹកទៅលើអ្នកដំណើរ ដែលពួកគេមានជំនឿថា ជាការប្រោះនូវសិរីសួស្តី និងលាងជម្រះភាពមិនល្អដែលតោងទាមយើងគ្រប់គ្នាតាំងពីឆ្នាំចាស់ គឺត្រូវលាងជម្រះចេញក្នុងឆ្នាំថ្មីនេះ។ នេះជាទំនៀមមួយដែលយើងមិនគួរបំភ្លេចឬបោះបង់ចោលនោះទេក្នុងវប្បធម៌ប្រពៃណីខ្មែរ ដែលទាក់ទងនិងកិច្ចពិធីស្រង់ព្រះពុទ្ធអង្គ និងស្រង់ព្រះរស់ដែលជាឪពុកម្តាយជីដូនជីតារបស់យើង និងការប្រោះព្រំទឹកក៏ដូចជាការលេងល្បែងប្រជាប្រិយផងដែរ។

## ៤. ល្បែងប្រជាប្រិយមួយចំនួន និងរបាំត្រុដិក្នុងទំនៀមចូលឆ្នាំ

ល្បែងប្រជាប្រិយ ជាទូទៅគេច្រើនតែលេងនៅក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។ ចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ គឺជាពិធីបុណ្យចូលឆ្នាំថ្មីរបស់កម្ពុជា ដែលកំណត់តាមប្រតិទិនពុទ្ធសាសនា តាមដំណើរគោចររបស់ព្រះចន្ទ ដែលរាប់តាមរង្វាស់នៃឆ្នាំចន្ទគតិ នៅក្នុងវប្បធម៌ខ្មែរ។ ពិធីបុណ្យនេះត្រូវបានគេហៅថា ពិធីបុណ្យគិម្ហៈរដូវ " បុណ្យរដូវក្តៅ" នៃរិស្សមកាលតូច ដែលបានមកពីអរិយធម៌នៃវប្បធម៌ប្រទេសឥណ្ឌា ដែលហៅថ្ងៃចូលឆ្នាំថ្មីថា "សង្ក្រាន្ត" (Sangkranta)។ ពាក្យ **សង្ក្រាន្ត** ជាភាសាដើមនៃពាក្យ(សំស្ក្រឹត) ដែលត្រូវបានប្រជាជនខ្មែរឱ្យនិយមន័យថា (សង្ក្រាន្តខ្មែរ)។ សង្ក្រាន្តគឺជាថ្ងៃចូលឆ្នាំថ្មី ដែលប្រារព្ធឡើងរៀងរាល់ថ្ងៃទី១៣ឬថ្ងៃទី១៤ ខែមេសា ជារៀងរាល់ឆ្នាំ ដែលប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវបានឈប់សម្រាកពីការងារដើម្បីចូលរួមអបអរថ្ងៃចូលឆ្នាំថ្មី។ ជាទូទៅមុនថ្ងៃចូលឆ្នាំថ្មីប្រពៃណីខ្មែរមកដល់ ប្រជាជនខ្មែរគ្រប់រូបនឹងធ្វើដំណើរនិវត្តពីគ្រប់ទិសទីមកស្រុកកំណើតរបស់ខ្លួនវិញ ដើម្បីជួបជុំក្រុមគ្រួសាររៀងរាល់មួយឆ្នាំ

ម្តង។ នៅមុនថ្ងៃចូលឆ្នាំ ប្រជាជនខ្មែរតែងតែរៀបចំសម្អាតនិងតុបតែងលម្អផ្ទះសម្បែង ដោយផ្ទះខ្លះក៏ព្យួរគោមផ្កាយ ផ្ទះខ្លះក៏ដាក់ភ្លើងពណ៌ ដែលគេមានជំនឿថា ពន្លឺគោមផ្កាយនិងភ្លើងពណ៌ទាំងនោះ នឹងនាំមកនូវសិរីសួស្តី លាភសំណាង និងភាពមានបានផងដែរ។ ក្រៅពីនេះទៀតមានលេងល្បែងប្រជាប្រិយខ្មែរដើម្បីកម្សាន្តនៅតាមភូមិស្រុករបស់ពួកគេផងដែរ ដូចជា៖ ចោលឈូង បោះអង្គុញ លាក់កន្សែង ទាញព្រ័ត្រ ស្តេចចង់ វាយក្អម ដណ្តើមស្លឹកឈើ ចាប់កូនខ្លែងប្រលែងកូនមាន់ ជាដើម។

សូមបញ្ជាក់ថា ល្បែងប្រជាប្រិយខ្មែរ បានបង្កើតឡើងតាំងពីយូរលង់ណាស់មក ហើយដែលកើតតាមរយៈជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋខ្មែរតាមសម័យកាលនីមួយៗ ពោលគឺមានប្រភពចេញពីកម្លាំងពលកម្មការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងជាការចេះចាំតៗគ្នា។

នៅរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ ប្រទេសកម្ពុជានឹងរៀបចំនូវពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ខ្មែរ ដែលក្នុងនោះប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានជំរុញលើកទឹកចិត្តឱ្យគ្រប់បណ្តាខេត្ត-រាជធានី ដឹកនាំពលរដ្ឋ ឱ្យលេងល្បែងប្រជាប្រិយខ្មែរ ក្នុងបំណងដើម្បីការពារ ថែរក្សា វប្បធម៌ប្រពៃណីដូនតាខ្មែរផងដែរ នាងខ្ញុំសូមលើកយកនូវល្បែងប្រជាប្រិយមួយចំនួនមកបង្ហាញដូចតទៅ៖

. **ល្បែងឈូង** ជាល្បែងម្យ៉ាងរបស់មនុស្សប្រុសស្រីទូទាំងកម្ពុជរដ្ឋនិយមលេង ហើយគេតែងលេងនៅពេលយប់ ខែភ្លឺ ក្នុងរដូវចូលឆ្នាំថ្មី (ខែចេត្រ ពិសាខ)។ គេចែកគ្នាជា២ក្រុម គឺប្រុស១ក្រុម និងស្រី១ក្រុម។ ក្នុង១ក្រុមៗ មានគ្នាចំនួនពី១០នាក់ ឬ២០នាក់ឡើងទៅ ដោយឈរត្រៀមជា២ជួរ ទល់មុខគ្នា ឃ្លាតពីគ្នាប្រមាណជា៨ ឬ១០ ម៉ែត្រ។ មុននឹងលេង គេយកក្រមា ឬកន្សែងមកធ្វើឱ្យមូល ចងវិតឱ្យតឹងណែនល្អ ទុកឱ្យមានកន្ទុយបន្តិចហៅថា «ឈូង» សម្រាប់កាន់បោះ ឬចោលទៅមករកគ្នា។ ការលេងឈូងមាន២បែប គឺឈូងច្រៀងរាំ និងឈូងលោះខ្ញុំ ដែលអាស្រ័យលើការសន្មត់គ្នាមុនលេង។ ល្បែងនេះគេលេងដើម្បីហាត់ភ្នែកឱ្យវៃ ដៃឱ្យរហ័ស តម្រង់ឱ្យត្រង់ ឱ្យមានស្មារតីប្រុងប្រយ័ត្ន ហាត់ទម្លាប់ខ្លួនឱ្យចេះប្រុងស្មារតី។

. **ល្បែងបោះអង្គញ់** គឺជាល្បែងមួយដែលគេឱ្យឈ្មោះទៅតាមវត្ថុដែលគេយកមកលេង គឺផ្លែអង្គញ់ដែលក្រៀមស្ងួត។ ល្បែងនេះ គេលេងបានទាំងប្រុសទាំងស្រី ទាំងចាស់ទាំងក្មេង នៅវេលាថ្ងៃ ឬយប់ខែភ្លឺ នារដូវចូលឆ្នាំ។ ល្បែងនេះ គេលេងបានចាប់ពីគ្នា២នាក់ឡើងទៅ រហូតដល់១០នាក់ ឬលើសពីនេះ ដោយចែកចេញជាពីរក្រុមមានចំនួនស្មើគ្នា។ អង្គញ់ដែលគេយកមកលេងគេឱ្យឈ្មោះថា កោយ[1] ដែលចែកចេញជាពីរផ្នែក គឺកោយដាំ និងកោយបោះ។ បើកោយដាំនោះមានចំនួន៣ ឬចំនួន៥ គឺថាកោយបោះក៏មានចំនួនតាមកោយដាំដែរ និងអាស្រ័យលើអ្នកលេងមានតិច ឬច្រើន តែតំបន់ខ្លះ ក៏លេងមិនកំណត់ចំនួនកោយស្មើនឹងចំនួនអ្នកលេងដែរ។ លុះសន្មត់គ្នាហើយ ក្រុមនីមួយៗក៏នាំគ្នាបោះអង្គញ់តម្រង់ទៅកោយដែលដាំឱ្យត្រូវ។ ក្រុមណាបោះត្រូវច្រើនជាង ក្រុមនោះគឺជាអ្នកឈ្នះ តែត្រូវចៀសការបោះចំកោយកណ្ដាលដែលនាំឱ្យចាញ់គេវិញ។ ចំពោះអ្នកឈ្នះគេយកអង្គញ់ពីរមកដាក់ផ្ដោបគ្នាដោយដាក់អង្គញ់ ១ផ្ដេក ១ទៀតបញ្ឈរ ទុកចន្លោះឱ្យឃ្លាតគ្នាបន្តិចដើម្បីជួសទៅនឹងជង្គង់អ្នកចាញ់ឱ្យត្រូវ បើជួសមិនត្រូវ នោះអ្នកចាញ់មានសិទ្ធិជួសអ្នកឈ្នះវិញ។

. **ល្បែងលាក់កន្សែង** ជាល្បែងម្យ៉ាងរបស់ប្រជាជាតិខ្មែរក្នុងសម័យបុរាណកាល ដែលជាជាទូទៅច្រើនតែក្មេងៗជាអ្នកលេង ព្រោះត្រូវរត់លឿន ហើយគេតែងតែលេងសម្រាប់ជាទីកម្សាន្តសប្បាយនៅពេលរាត្រីខែភ្លឺ ក្នុងរដូវចូលឆ្នាំ ឬនៅពេលចន្លោះការហាត់នឿយម្ដងៗ។ មុនដំបូង គេបបួលគ្នាបានចំនួនពី ៦-៧ នាក់ឡើងទៅ ឱ្យអង្គុយប្រហោង ដំកង់ជារង្វង់មូល ដោយដាក់ដៃទាំងពីរទៅមុខលើក្បាលជង្គង់ នាទីកន្លែងណាមួយដែលជាទីស្រឡះរាបស្មើល្អ ហើយគេយកកន្សែង ឬក្រមាតូចមួយមករុំមូរធ្វលរឹតឱ្យតឹងណែនល្អជាទ្រវែង ទុកជាយបន្តិចសម្រាប់កាន់យួរបាន ដែលគេសន្មតហៅថា «**កន្សែង**» ដោយមានម្នាក់ក្រោកចេញទៅក្រៅវង់ កាន់កន្សែងនោះ ដើរព័ទ្ធជុំវិញយ៉ាងលឿនពីខាងក្រោយខ្នងអ្នកអង្គុយ បញ្ឆោតអ្នកអង្គុយមិនឱ្យដឹងខ្លួនថាគេលាក់កន្សែង

[1] កោយ មានន័យថា មេអង្គញ់។

ក្រោយខ្នងអ្នកណាម្នាក់ទេ ហើយអ្នកដែលត្រូវគេដាក់កន្សែងនោះ បើបានដឹងហើយត្រូវតែក្រោកឡើងឱ្យរហ័ស ដេញវាយអ្នកអង្គុយបន្ទាប់ ហើយអ្នកអង្គុយបន្ទាប់នោះត្រូវក្រោករត់១ជុំ គេចពីការដេញវាយនោះ មកអង្គុយកន្លែងខ្លួនវិញ ទើបអ្នកវាយនោះដើរលាក់កន្សែងជាបន្ត។

. **ល្បែងទាញព្រ័ត្រ** ជាល្បែងលេងកម្សាន្តសប្បាយរបស់យុវជនខ្មែរទាំងបុរសទាំងស្ត្រី។ ល្បែងនេះគេលេងដោយប្រើកម្លាំងកាយ ហើយគេលេងតែក្នុងរដូវចូលឆ្នាំខ្មែរ គឺខែចេត្រ ពិសាខប៉ុណ្ណោះ។ មុនដំបូងគេចែកអ្នកលេងជា២ក្រុម ១ក្រុមពី១០ទៅ២០នាក់ ដោយរើសរកប្រុសម្នាក់ ស្រីម្នាក់ មានមាឌធំមាំ កម្លាំងខ្លាំង ជាអ្នកឈរកាន់ខាងចុងព្រ័ត្រ គឺប្រុសកាន់ម្ខាង ស្រីកាន់ម្ខាង និងឱ្យបុរសម្នាក់ និងស្ត្រីម្នាក់ទៀតមានមាឌធំ មានកម្លាំង ឈរកណ្តាលព្រ័ត្រ ត្រង់កន្លែងដែលគេចងបន្តោងខ្សែចំណាំថាជាចំណុចកណ្តាលនៃព្រ័ត្រ គឺអ្នកទាំងពីរឈរសម្រាប់នាំក្រុមខ្លួនឱ្យខំទាញតែរៀងៗខ្លួន។ ឯមនុស្សដែលមានមាឌតូចៗ ស្គមៗ កម្លាំងខ្សោយៗ គេឱ្យឈរកណ្តាលគេ។ លុះរៀបចំរួចហើយ គេឱ្យមនុស្សប្រុសម្នាក់កាន់សំភោរ ឬគងម៉ង់ ឬក៏រគាំងឈរត្រង់កណ្តាលទីជិតអ្នកទាំងពីរដែលកាន់ខ្សែឈរប្រទល់មុខគ្នានោះ ផ្តើមស្រែកឡើងព្រមគ្នាថា យក្សអរ !.! ឱ្យឮខ្លាំងៗ ធ្វើសំឡេងវែងៗ រលាក់រលែកយ៉ាងគ្រលួច ហើយអ្នកប្រកួត ដែលជាអ្នកប្រុងទាញព្រ័ត្រទាំងប៉ុន្មាន ជួយស្រែកឡើងព្រមៗគ្នា ហ៊ោ៣ដង ទើបនាំគ្នាទាញយកជ័យជម្នះរៀងៗខ្លួន។

. **ល្បែងចាប់កូនខ្លែង** ជាល្បែងមួយតែងលេងក្នុងវេលាយប់ខែភ្លឺ នៅរដូវចូលឆ្នាំ ឬនៅពេលទំនេរ។ ល្បែងនេះ ពេលលេងគេចាត់ម្នាក់ដែលមានមាឌធំ ឱ្យធ្វើជាមេហ្វូង ហៅថាមេមាន់ និងចាត់ច្រើននាក់ឱ្យធ្វើជាកូនមាន់ ហើយគេចាត់ម្នាក់ទៀតឱ្យធ្វើជាខ្លែង ចាំចាប់កូនមាន់។ បន្ទាប់មកគេយកក្រមាក្រវាត់ចង្កេះមេមាន់ឱ្យតឹងណែនការពារកុំឱ្យរបូតសម្លៀកបំពាក់។ គេនាំគ្នាបង្កាត់ភ្លើងឱ្យបានជាគ្នក់១តូច ដោយកំទេចអុស ហើយអ្នកធ្វើមេមាន់បញ្ជាឱ្យកូនៗរបស់ខ្លួនតោងចង្កេះតៗគ្នារហូតអស់គ្នា ដោយឈរជាជួរ រួចដើរក្រឡឹងព័ទ្ធជុំភ្នក់ភ្លើង។ ជាមួយគ្នានេះមេមាន់ពោលពាក្យចំអកឡកឡឺយឱ្យន័យទៅខ្លែងថា៖ ចាប់កូនខ្លែងប្រលែងកូនអក ពពេចញ៉ែកញ៉ក កូនអញ

តែមួយៗ ដីកអន្ទុងដាំត្រកួន ទន្សាយរត់ពួន ត្រកួនឡើងលាស់ៗ ទៀន១គូតាំងយូបាំងព្រះ លើកដៃសំពះ ដូនៗសុំភ្លើងៗ

ចំណែកអ្នកដែលធ្វើខ្លែង គឺឈរធ្វើព្រងើយ តែកាលបានឮមាន់និងកូនមាន់ស្រែកដូច្នេះហើយ ក៏ដើរចូលទៅរកក្អកភ្លើង ហើយនិយាយសុំភ្លើងថា«ដូនៗសុំភ្លើង!»ៗ មាន់ឆ្លើយ«រលត់»ៗ ខ្លែងសុំថា«សុំ១អង្កត់»ៗ មាន់ថា «មិនឱ្យ »ៗ ខ្លែងថា «ចុះបើសុំកូនក្រោយ »ៗ មាន់ថា «ចាប់បានយកចុះ»ៗ

ខ្លែងកាលបានឮមេមាន់ថា ឱ្យកូនក្រោយ ឬកូនណាកំបាក់កំបែកដូច្នេះ ក៏តាំងដេញចាប់បេះយកកូនណាដែលនៅក្រោយគេ ហើយមេមាន់ខំការពារកូនរបស់ខ្លួនកុំឱ្យគេបេះយកបាន ឯកូនមាន់ក៏ខំប្រឹងតោងចង្កេះគ្នាយ៉ាងជាប់ រត់ពេនចុះពេនឡើង ខ្លាចខ្លែងចាប់បេះយកខ្លួនម្នាក់ៗបានៗ ជួនខ្លែងបេះយកកូនបានម្តង១ៗទាល់តែអស់ ជួនក៏បេះបានតែ១ៗ តែគេមានលក្ខខ័ណ្ឌមួយថា បើកូនណារបូតចេញពីមេព្រោះប្រឹងគេចខ្លាំងហើយកូននោះគេក្រាបទៅនឹងដីនោះ មេខ្លែងមិនត្រូវចាប់គេទេៗ កាលអស់កម្លាំងហត់រៀងខ្លួនហើយ ក៏ឈប់សម្រាកបន្តិច ហើយផ្លាស់ប្តូរគ្នាលេងតទៅទៀត គេលេងតែងរបៀបនេះរហូតដល់ពេលឈប់ៗ ប៉ុន្តែល្បែងដូចគ្នានេះ នៅស្រុកខ្លះ គេហៅតម្រូវន័យតាមរបៀបលេងថា«ល្បែងខ្លែងចាប់កូនមាន់»ក៏មានៗ ល្បែងនេះ ជាការបង្ហាត់មនុស្សឱ្យចេះប្រុងស្មារតីឱ្យ មានភាពរហ័សរហួន ចេះការពារខ្លួននិងគ្រួសារៗ

### . ល្បែងដណ្តើមស្លឹកឈើ

ចំពោះការលេងល្បែងនេះ គឺគេរើសបុរសនិងនារីមួយគូរ ឬច្រើនគូរ ឱ្យចូលលេង ដោយមានអាជ្ញាកណ្តាលម្នាក់ជាអ្នករាប់ រួចដាក់ស្លឹកឈើឱ្យនៅចំកណ្តាល ហើយរាប់ដល់៣ បើអ្នកណារត់មកដណ្តើមស្លឹកឈើបានមុន ចាត់ទុកថាជាអ្នកឈ្នះ ចំណែកអ្នកដែលចាញ់ត្រូវទទួលពិន័យដោយឱ្យច្រៀង រាំជាដើមៗ ល្បែងដណ្តើមស្លឹកឈើ មិនត្រឹមតែផ្តល់នូវភាពសប្បាយរីករាយប៉ុណ្ណោះទេ ថែមទាំងបង្រៀនមនុស្ស ឱ្យមានភាពវាងវៃ ស្វាហាប់ និងរហ័សរហួនៗ

### ល្បែងស្តេចចង់

ល្បែងស្តេចចង់ គឺជាល្បែងប្រពៃណីខ្មែរសម្រាប់លេងកម្សាន្ត ដោយចែកម្ខាងប្រុស រីឯម្ខាងទៀតស្រី និងមិនកំណត់ចំនួន

ឡើយ ហើយគេជ្រើសរើសមនុស្សម្នាក់ឱ្យធ្វើជា«ស្តេច»[2] ដែលអង្គុយចំកណ្តាល រង់ចាំការមកខ្សឹបប្រាប់នៃក្រុមម្ខាងៗ ម្នាក់ម្តងៗ ថាស្រឡាញ់ ឬពេញចិត្តអ្នកណា? ហើយស្តេចត្រូវតែរក្សាភាពស្មោះត្រង់នោះ។

ចំពោះអត្ថន័យនៃល្បែងនេះ គឺបង្កប់នូវការអប់រំ ឱ្យយើងចេះជ្រើសរើសមេដឹកនាំរបស់ខ្លួនឱ្យបានត្រឹមត្រូវ បង្ហាត់ចិត្តមនុស្សចេះប្រកាន់ពាក្យសច្ចៈយុត្តិធម៌ ត្រឹមត្រូវ។

**. របាំត្រុដិ**

របាំត្រុដិ ជារបាំមួយដែលគេរាំក្នុងពេលចូលឆ្នាំ ដែលកើតឡើងពីជនជាតិសំរែ ជាជនជាតិដើមមួយនៅលើទឹកដីយើងក្នុងអំបូរខ្មែរ-មន។ ជនជាតិសំរែរស់នៅត្រង់ម្តុំក្បែរអង្គរ ខេត្តសៀមរាប។ របាំត្រុដិផ្សារភ្ជាប់នឹងជំនឿបន់ស្រន់ទឹកភ្លៀង។ ក្នុងរបាំនេះ គេនិយមប្រើកន្ទុយក្ងោក ដែលគេយល់ថាក្ងោកជាតំណាងព្រះអាទិត្យ។ មនុស្សបន់ស្រន់អង្វរកព្រះអាទិត្យឱ្យធ្វើអំណោយទឹកភ្លៀងគ្រប់គ្រាន់សម្រាប់ធ្វើស្រែចម្ការ។ នៅពេលគ្មានភ្លៀងធ្លាក់ គេលេងត្រុដិដើម្បីបួងសួងសុំទឹកភ្លៀង។ របាំត្រុដិលេងនៅពេលចូលឆ្នាំ គឺគេលេងថ្វាយព្រះអាទិត្យអង្វរកឱ្យហើយស្រេចតាំងពីដើមឆ្នាំ សុំទឹកភ្លៀងសម្រាប់វស្សារដូវខាងមុខនេះ។

ពាក្យថា ត្រស្តិ ក្លាយមកពីភាសាសំស្ក្រឹតថា ត្រុដ កិ. "កាត់ ផ្តាច់" ត្រុដិ ន. "ដំណើរកាត់ ការផ្តាច់" ក្នុងព្រះរាជពិធីនេះ សំដៅយកសេចក្តីថា "ដំណើរផ្តាច់ឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មី។

ការរាំរបាំត្រុដិនាពេលចូលឆ្នាំថ្មី គឺគេកំណត់យកដំណើរផ្តាច់ឆ្នាំនីមួយៗដើម្បីដេញឧបទ្រពចង្រៃដែលកើតមានក្នុងឆ្នាំចាស់ ហើយនិងប្រសិទ្ធពរសព្ទសាធុការក្នុងឱកាសឆ្នាំថ្មីវិញ។ តាមរយៈការសម្តែងគឺប្រជាពលរដ្ឋយើងតែងតែមានសេចក្តីសប្បាយរីករាយណាស់ព្រោះអ្នករាំរបាំត្រុដិបានចូលទៅដល់មុខផ្ទះឬក្នុងភូមិ ខណៈពេលដែលពួកគាត់មានជំនឿប្រកបដោយក្តីសង្ឃឹមថា ក្នុងឆ្នាំថ្មីនេះ សុភមង្គលលាភ

[2] ល្បែងនេះ មានតំណាលថា សម័យថ្ងៃមួយ ព្រះបាទ ឥន្ទ្របត្តបុរី ក្នុងឱកាសព្រះរាជពិធីមួយ ដែលមានក្រុមញាតិវង្សនិងមហាមន្ត្រីជាច្រើន ទ្រង់ប្រឌិតល្បែងនេះឡើង ដើម្បីជាការកម្សាន្ត ហើយក៏ត្រូវបានប្រជារាស្ត្រលេងត្រាប់តាម រហូតមកដល់សព្វថ្ងៃនេះ។

សក្ការៈនឹងកើតមានក្នុងក្រុមគ្រួសារឬភូមិស្រុករបស់គាត់មិនខាន។ ជាទូទៅគេសម្តែងរបាំត្រុដិនេះពាសពេញភូមិតែម្តង ប្រសិនបើជាមានសត្វព្រៃរត់ចូលភូមិស្រុករបស់គេ ព្រោះគេមានជំនឿថា ពេលណាមានសត្វព្រៃដូចជាឈ្លូស ប្រើស រមាំង ជាដើម រត់ចូលភូមិក្នុងករណីណាក៏ដោយ ពួកគេនឹងចាត់ទុកថា នោះគឺជាអព្ភូតហូតហេតុអាក្រក់ ឬចង្រៃ ហើយត្រូវអញ្ជើញក្រុមរបាំត្រុដិមកលេងដើម្បីបណ្តេញភាពចង្រៃនោះចេញ ។ ប៉ុន្តែប្រសិនបើគេចាប់បានពពួកសត្វព្រៃនោះវិញ គឺគេយកវាទៅលាបប្រេងម្សៅ ហើយធ្វើពិធីលែងឱ្យមានសេរីភាពវិញ ដោយបួងសួងសុំសេចក្តីសុខសប្បាយប្រជាពលរដ្ឋក្នុងភូមិ ស្រុក ពេលដែលគេមានជំនឿថា សត្វព្រៃទាំងនោះបានមករំដោះគ្រោះមហន្តរាយដល់ពួកគេ ។

## ឧបករណ៍សម្តែង និងឧបករណ៍តន្ត្រី

***កញ្ជារ៖*** ដងធ្វើពីពីងពង់ប្រវែង២ម៉ែត្រ មានបន្ទះរនាបតូចឆ្មារភ្ជាប់នៅចុង ហើយខ្វែងពីចុង១ទៅចុង១ ហើយត្រង់កណ្តាលខ្សែខ្វែងនេះមានបន្តោងផ្លែអង្គុញដែលចោះយកគ្រាប់ចេញអស់ ហើយដាក់គ្រាប់គ្រួស ឬដែកទៅក្នុងនោះ ប្រយោជន៍ឱ្យឮសូរ កាលណាគេបុកដងវាទៅនឹងដីតាមចង្វាក់ស្គរ។

***ចង្រ្វង់ដំបែ៖*** ចង្រ្វង់បន្តោងនឹងខ្សែទាមគោហើយចងភ្ជាប់ដងឫស្សីដែរ។ កាលបើគេបុកនឹងដី ក៏លាន់សូរច្រាវ តាមចង្វាក់។

***ចង្រ្វង់រ៉ូង៖*** ចង្រ្វង់នេះចងព្យួរនឹងចង្កេះមនុស្សតែម្តង ដោយចងគួបគ្នាជាចង្កោមៗ។

***ស្គរ៖*** ធ្វើពីដីដុតពាសស្បែកថ្លាន់។

*ប៉ីពក ទ្រអ៊ូ ទ្រសោ។*

***សន្ទូច៖*** ដងពីងពង់វែងមានសណ្ឋានដូចសន្ទូច ចុងដូចចន្ទោលរទេះ ដោយមានព្យួរថង់មួយនៅចុង សម្រាប់ទទួលវត្ថុជាទាន។

- ឧបរណ៍តែង

***មុខត្លុក៖*** ធ្វើពីធ្លឹងឫស្សី ពាសក្រដាស ឬ ស្នាច់ ឬ ខ្នុក។

***មកុដ៖*** ក្រដាសលាបកាវ បិទតម្រូវគ្នាទៅជារឹង គឺស្នាច់ឬខ្នុក ហើយផាត់ពណ៌។

*ស្នែងប្រើស ស្នែងទន្សោង កន្ទុយក្ងោក។*

**ក្របក៖** យកផ្ដៅប្រវែង០,២ម៉ែត្រ បិតចុងឱ្យស្រួច ពេលភ្លើងឱ្យង យកអំបោះចងគល់ភ្ជាប់នឹងម្រាម៤ ឯមេដៃមិនពាក់ទេ។

**+ តួសម្ដែងមាន** អ្នកពាក់មុខខ្មៅធ្វើមនុស្សព្រៃ អ្នកពាក់មុខត្នុកធ្វើព្រានព្រៃ អ្នកពាក់ស្នែងប្រើសនិងស្នែងទន្សោង តួរាំ (តួឯកនិងតួនាង ) អ្នកពាក់ក្របក អ្នកកាន់គ្រឿងភ្លេង ដែលតួសម្ដែងសរុបក្នុងរបាំត្រុដិជាមធ្យមមានម្ភៃប្រាំនាក់។

**+ របៀបសម្ដែង**

- ដំបូងបង្អស់តួសំដែងទាំងអស់ត្រូវបន្ទន់កាយរំលឹកគុណគ្រូ។ អ្នកពាក់មុខទាំងអស់(មនុស្សព្រៃ ព្រានព្រៃ) ចេញមកមានកិរិយាមិននឹងធឹង ច្រើនរត់វេច្ឆេងស្ដាំ ចេញក្រៅពីវង់ ហើយច្រើនរត់ទៅមុខគេ។ ដងខ្លួនធ្វើងេកងោកយោលទៅតាមចង្វាក់ស្គរ ដៃគ្រាន់តែពត់បន្តិចមិនពេញជារាំទេ។ តួព្រានស្លៀកស្លឹកចេកច្រៀក ចងព័ន្ធចង្កេះ លាបខ្លួនខ្មៅ។

អ្នកពាក់ស្នែង (ប្រើស ទន្សោង) ចាក់ក្បាច់ប្រហែលព្រាននិងមនុស្សព្រៃដែរ។ ដៃទាំងពីរជួនយកទៅកាន់ស្នែង ជួនលូកទៅមុខទំនងធ្វើជាដើងម្រឹគ ដោយបង្អោនខ្លួន។ គេរាំលោតៗតាមចង្វាក់ ស្គរផ្អៀងផ្អងដូចម្រឹគផ្អើលម្ដងៗ។ យូរៗប្រើសនិងទន្សោងធ្វើជារត់ចេញខាងក្រៅវង់ម្ដងៗដែរ។

តួឯក និង តួនាងច្រើនជាតួរាំនារី។ តួឯកពីរនាក់ស្លៀកចងក្បិនពណ៌ ពាក់អាវពណ៌ ពាក់របៃ គ្មានសង្វារ ហើយបង់កន្សែងពណ៌សំយុង។ តួរាំពីរគូនេះ មានក្បាច់ទន់ភ្លន់ជាងគេ ដោយមានឫកជានារីក្រមុំអែនអន កែក្រាយ។

អ្នកពាក់ក្របក និង អ្នកកាន់គ្រឿងភ្លេង ជាតួបន្ទាប់បន្សំ។ អ្នកពាក់ក្របកជួយច្រៀង និងឱ្យចង្វាក់ជួយបង្កើនទស្សនីយភាពនៃវង់របាំ។ អ្នកកាន់គ្រឿងភ្លេង ជាពិសេសអ្នកបុកកញ្ជារ និងអ្នកកាន់ចង្រ្កងដំបែជួយចង្វាក់ស្គរ យោលខ្លួនចុះឡើងតាមចង្វាក់ស្គរនិងកញ្ជារ។

**+ ទំនុកច្រៀង៖**

វង់ត្រុដិស្រុកអាយវង់ត្រុដិស្រុកអាយលំឱនអង្គកាយ សូមពរឆ្នាំថ្មី។ បន្ទរ៖ ឱណានាងណា សូមពរឆ្នាំថ្មី !

ផ្គរលាន់ឯត្បូង ត្រយូងចេកជ្វា អ្នកអើយត្រុដិលា ឈប់លេងត្រឹមណេះៗ បន្ទរ៖ ណា នាងណា ឈប់លេងត្រឹមណេះ!

កំណត់សម្គាល់៖ ចំពោះទំនុកច្រៀងទោះបីមានគំលាតពីន័យដើមពីសំណូមពរសុំទឹកភ្លៀង ក៏យើងឃើញទំនុកច្រៀងក្នុងរបាំនេះនៅមានសំណល់ជាតុខ្វះដែលមានក្នុងអាជីវកម្ម កសិកម្ម គឺបញ្ហាទឹកៗ យើងយល់ថា របាំត្រុដិត្រូវបានជនជាតិសំរែប្រើបសម្រាប់ដោះស្រាយសំណូមពរកសិកម្មដើម្បីទ្រទ្រង់ជីវិតរស់នៅៗ ប៉ុន្តែឆ្លងកាត់ដំណាក់កាលវិវត្តនៃប្រវត្តិសាស្ត្រសង្គមមនុស្ស របាំត្រុដិត្រូវបានទទួលឥទ្ធិពលខ្លាំងពីសាសនា ហើយត្រូវបានគេយកមកប្រើក្នុងបំណងផ្សេងទៅវិញៗ

ចំពោះការសម្តែងរបាំត្រុដិនៅតាមភូមិនីមួយៗកាលពីសម័យដើមវិញ គឺមានការតុបតែងខ្លួនជាលក្ខណៈសាមញ្ញ ហើយគេដើរដង្ហែជាក្បួនទៅមុខ ដោយមានអ្នកកាន់ដងចន្ទោលដែលមានការចងកំណាត់លម្អ និងមានសិល្បករម្នាក់ជាអ្នករាំនាំផ្លូវៗ តាមអ្វីដែលយើងបានឃើញពិធីរាំនោះ គឺមើលទៅហាក់ដូចជាអ្នករាំ ឬអ្នកហែទាំងនោះកំពុងតែជិះលើរទេះមួយដូច្នេះដែរៗ ចំណែកនៅខាងចុងនៃដងចន្ទោលនោះមានចងកូនថង់មួសម្រាប់ជាការរែអង្គាសប្រាក់ ហើយអ្នកផ្ទះឬអ្នកភូមិ ដែលមកឈរមើលការរាំរបាំត្រុដិនិងមានសទ្ធាជ្រះថ្លា ពួកគេនឹងដាក់ប្រាក់ក្នុងថង់នោះ ព្រោះគេមានជំនឿថាបុណ្យកុសលដែលបានដាក់ទាននាពេលនេះ នឹងបានចម្លងគ្រោះកាចចង្រៃនៃឆ្នាំចាស់ទៅអស់ ហើយចូលឆ្នាំថ្មីសិរីសួស្តីសុភមង្គលនឹងមកដល់ៗ

ជាសរុបសេចក្តី ពិធីបុណ្យចូលឆ្នាំជាពិធីបុណ្យមួយដែលល្អនៅក្នុងប្រពៃណីខ្មែរ ជាពិធីបុណ្យផ្តាច់ឆ្នាំចាស់ផ្លាស់ឆ្នាំថ្មី ជាពិធីបុណ្យនៃការវិលមកត្រលប់ជួបជុំគ្នា សួរសុខទុក្ខគ្នា ដើម្បីទទួលទេវតាឆ្នាំថ្មីឆ្នាំថ្មី បួងសួងសុំពរជ័យសិរីមង្គលវិបុលសុខ និងជាប្រពៃណីបណ្តុះនូវស្មារតីស្រឡាញ់រាប់អានគ្នាមិនត្រឹមតែជាបងប្អូនសាច់ញាតិ គឺរវាងអ្នកភូមិស្រុកជិតខាងគ្នា ដែលជាកត្តាបង្កើតសាមគ្គីភាពជាតិផងដែរ ដ្បិតពេលចូលឆ្នាំគេមិនត្រឹមតែជួបជុំគ្នាក្នុងគ្រួសារប៉ុណ្ណោះទេ តែគេនាំគ្នាទៅធ្វើបុណ្យនៅវត្តអារាម ដែលជាមជ្ឈមណ្ឌលអប់រំឱ្យមានមនុស្សធម៌ និងសាមគ្គីធម៌ៗ ហេតុដូច្នេះហើយ ទើបពិធី

បុណ្យចូលឆ្នាំថ្មី មានអត្ថន័យយ៉ាងជ្រាលជ្រៅ ដែលធ្វើឱ្យខ្មែរយើងនិយមរាប់អានទុកជា ប្រពៃណីជាតិតាំងពីដើមរហូតមកដល់បច្ចុប្បន្នយើងនេះ។

ក្នុងនាមនាងខ្ញុំជាប្រជាពលេដ្ឋខ្មែរម្នាក់ នាងខ្ញុំសូមសំណូមពរឱ្យប្រជាជនខ្មែរទាំងអស់នាំគ្នាចូលរួមថែរក្សានូវប្រពៃណីនៃពីធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរឱ្យបានគង់វង់ និងអភិរក្សនូវរាល់ល្បែងប្រជាប្រិយ ក៏ដូចជារបាំខ្មែរដែលមាន ជាពិសេសរបាំត្រុដិ ដើម្បីបន្តនូវមរតកល្បែងទាំងនេះទុកឱ្យកូនចៅខ្មែរជំនាន់ក្រោយៗទៀត បានស្វែងយល់ បានលេងកម្សាន្ត ដ្បិតល្បែងប្រជាប្រិយទាំងនេះ មិនត្រឹមតែនាំមកនូវភាពសប្បាយរីករាយប៉ុណ្ណោះទេ គឺបានបង្កប់នូវអត្ថន័យ និងគោលបំណងច្បាស់លាស់សម្រាប់កូនចៅខ្មែរដូចជា ឱ្យមានសាមគ្គីភាព មិត្តភាពស្រឡាញ់រាប់អានគ្នា មានទឹកចិត្តក្លាហាន ទន់ភ្លន់តែមិនទន់ជ្រាយ រហ័សរហួន ឈ្លាសវៃ និងដើម្បីពង្រឹងកាយសម្បទាឱ្យរឹងមាំជាដើម ហើយអ្វីដែលពិសេសនិងមានតម្លៃមិនអាចកាត់ថ្លៃបាននោះ គឺជាមរតកវប្បធម៌ នៃប្រជាជាតិខ្មែរ ជាអត្តសញ្ញាណជាតិខ្មែរតាំងពីយូរលង់មកហើយ៕

## ឯកសារពិគ្រោះ


- ក្រសួងអប់រំ អក្សរសិល្ប៍ថ្នាក់ទី១០ ភ្នំពេញ ឆ្នាំ ១៩៩៧-៩៨។

. ជា វណ្ណី អក្សរសិល្ប៍ប្រជាប្រិយខ្មែរ ឆ្នាំ២០១៧។

- ពុទ្ធសាសនបណ្ឌិត្យ ប្រជុំរឿងព្រេងខ្មែរ ភាគ១ ដល់៩ ភ្នំពេញ ឆ្នាំ១៩៩៤។

- ពុទ្ធសាសនបណ្ឌិត្យ ល្បែងប្រជាប្រិយខ្មែរ ភ្នំពេញ ឆ្នាំ១៩៩៤។

- ពុទ្ធសាសនបណ្ឌិត្យ របាំប្រជាប្រិយខ្មែរ ភ្នំពេញ ឆ្នាំ១៩៩៤។

- ពុទ្ធសាសនបណ្ឌិត្យ ពិធីបុណ្យទ្វារទសមាស ភ្នំពេញ ឆ្នាំ១៩៩៤។

- ពៅ សាមី លក្ខណៈពិសេសនៃអក្សរសិល្ប៍ និងសិល្បៈ ភ្នំពេញ ឆ្នាំ១៩៩២។

- ហ៊ុន គឹមសៀ **មូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ** គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ ១៩៥៨។